**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៤៣៩៣ ព.ណ.ក.ក.ប

ថ្ងៃព្រហស្បតិ៍ ៤រោច ខែ កត្តិក ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨

## ជម្រាបជូន

**លោក/លោកស្រីនាយកក្រុមហ៊ុន** ATTWOOD IMPORT EXPORT Co., Ltd.

**កម្មវត្ថុ:** ករណីស្នើសុំកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលស្រាម៉ាក JOHNNIE WALKER និងHENNESSYក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**
- ប្រកាសស្តីពីនីតិវិធីសម្រាប់ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ របស់ក្រសួងពាណិជ្ជកម្ម
- លិខិតកត់ត្រាទទួលស្គាល់សិទ្ធិនាំចូលនិងចែកចាយផ្តាច់មុខ លេខ ២៧៦១ ពណ.ពកប.ទប.ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៦ ។

តបតាមកម្មវត្ថុនិងយោងខាងលើខ្ញុំសូមជម្រាបជូនលោក/លោកស្រីមេត្តាជ្រាបថា៖

- កិច្ចព្រមព្រៀងចែកចាយលើស្រាម៉ាក JOHNNIE WALKER ក្រសួងមិនអាចទទួលយកមកកត់ត្រានិងតម្កល់បានឡើយ ព្រោះម្ចាស់ម៉ាកបានប្តូរទៅជាម្ចាស់ម៉ាកថ្មីហើយ។
- កិច្ចព្រមព្រៀងចែកចាយលើស្រាម៉ាក HENNESSYក្រសួងមិនអាចទទួលយកមកកត់ត្រានិងតម្កល់បានឡើយ ព្រោះកិច្ចព្រមព្រៀងនេះបានផុតសុពលភាពហើយ។

ដើម្បីក្រសួងអាចចេញលិខិតកត់ត្រា និងតម្កល់សិទ្ធិផ្តាច់មុខបាន ក្រុមហ៊ុនត្រូវស្នើសុំលិខិតប្រគល់សិទ្ធិផ្តាច់មុខពីក្រុមហ៊ុនដែលជាម្ចាស់ម៉ាកសាជាថ្មី ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រី ជ្រាបជាព័ត៌មាន។

សូមលោក/លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469